**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
លេខ ០១៤.../គ.ជ.វ.វ

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង

- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងសេចក្តីសម្រេចលេខ០២២សសរ/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារគណនេយ្យភាពជាតិរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) សូមធ្វើការណែនាំដល់ខេត្ត ក្រុងទាំងអស់ដូចខាងក្រោម :

គ្រប់រដ្ឋបាលខេត្ត ក្រុងត្រូវបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ហៅកាត់ (ក.គ.ខ) ដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់វចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ ព្រមទាំងរួមចំណែកក្នុងការពង្រឹងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្របតាមគោលការណ៍ច្បាប់ ។

អភិបាលខេត្ត ក្រុងត្រូវចេញនូវសេចក្តីសម្រេច ដើម្បីបង្កើត ក.គ.ខ របស់ខ្លួន ។

### ១- សមាសភាពរបស់ ក.គ.ខ

រដ្ឋបាលខេត្ត ក្រុងត្រូវបង្កើត ក.គ.ខ ដែលមានសមាសភាពដូចខាងក្រោម ÷

១- អភិបាលខេត្ត ក្រុង ជាប្រធាន

២- អភិបាលរងខេត្ត ក្រុង ០២ រូប ជាអនុប្រធាន

៣- សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ជាសមាជិក

៤- សវនករផ្ទៃក្នុងខេត្ត ក្រុង ជាសមាជិក

៥- ប្រធានផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ជាសមាជិក

៦- ប្រធានផ្នែកគ្រប់គ្រងកិច្ចសន្យារបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ជាសមាជិក

៧- ប្រធានផ្នែកគាំទ្របច្ចេកទេសរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ជាសមាជិក

៨- ប្រធានរតនាគារខេត្ត ក្រុង ជាសមាជិក

៩- ប្រធានសាខាធនាគារជាតិនៃកម្ពុជាខេត្ត ក្រុង ជាសមាជិក

១០- ប្រធានសាខាពន្ធដារខេត្ត ក្រុង ជាសមាជិក

១១- តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន ០២ រូប ជាសមាជិក

១២- តំណាងអ្នកទទួលការចំនួន ០២ រូប ជាសមាជិក

១៣- តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុងចំនួន ០៣ រូប ជាសមាជិក

១៤- ប្រធានទីប្រឹក្សារបស់គម្រោង PSDD ប្រចាំខេត្ត ក្រុង ជាសមាជិក

១៥- ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ជាសមាជិក និងលេខាធិការ

ក.គ.ខ ត្រូវមានអាណត្តិស្មើនឹងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ក្នុងករណីសមាជិក ក.គ.ខ ណាមួយត្រូវបានផ្លាស់ប្តូរ លេខាធិការរបស់ ក.គ.ខ ត្រូវរៀបចំសំណើកែសម្រួលសមាសភាពក្រុមការងារនេះឡើងវិញ និងដាក់ជូន ក.គ.ខ ពិនិត្យ និងសម្រេច ដើម្បី ក.គ.ខ បន្តនិរន្តរភាពដំណើរការការងាររបស់ខ្លួន។

## ២- តួនាទី និងភារកិច្ចរបស់ ក.គ.ខ

ក.គ.ខ មានតួនាទីប្រមូលរាល់បញ្ហាដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ និងបញ្ហានៃការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីសម្របសម្រួលដោះស្រាយ និងចាត់វិធានការ ព្រមទាំងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ។

ក.គ.ខ ត្រូវមានភារកិច្ចដូចខាងក្រោម ÷

- ផ្សព្វផ្សាយអំពីគោលបំណង តួនាទី និងភារកិច្ច ព្រមទាំងនីតិវិធីធ្វើការងាររបស់ខ្លួនឱ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ
- ប្រមូល និងទទួលរបាយការណ៍ និងពាក្យបណ្តឹងតវ៉ាឱ្យបានជាប្រចាំ ដែលពាក់ព័ន្ធបញ្ហាមិនប្រក្រតីនៃការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតក្រោមផែនការ

សកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ និងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

- ត្រូវធានានូវការសម្ងាត់ចំពោះការផ្ដល់របាយការណ៍ និងពាក្យបណ្ដឹងតវ៉ាពីអ្នកពាក់ព័ន្ធ
- ពិនិត្យ ពិភាក្សា និងដោះស្រាយរាល់របាយការណ៍ ព័ត៌មាន និងបណ្ដឹងតវ៉ា ដែលទទួលបានពីអ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ
- មិនត្រូវព្យួរទុកនូវករណីដែលបានរាយការណ៍ ឬបណ្ដឹងតវ៉ាណាមួយ ដែលទទួលបានលើសពីមួយខែបន្ទាប់ពីថ្ងៃដែលបានទទួល ឬប្រមូល
- រៀបចំ និងចុះស៊ើបអង្កេតបញ្ហានានា ដែលបានលើកឡើងនៅក្នុងរបាយការណ៍ ក្នុងករណីចាំបាច់
- កំណត់វិធានការដាក់វិន័យ ឬទណ្ឌកម្ម ចំពោះបុគ្គលណាដែលមានការពាក់ព័ន្ធនឹងបញ្ហាដែលបានកើតឡើងក្នុងរបាយការណ៍ ឬពាក្យបណ្ដឹងតវ៉ា
- ស្នើសុំទៅក្រសួង ស្ថាប័ន ឬអង្គភាពសាមី ដើម្បីដាក់វិន័យ ឬទណ្ឌកម្មចំពោះបុគ្គលណាដែលបានប្រព្រឹត្តសកម្មភាពពាក់ព័ន្ធនឹងបញ្ហាមិនប្រក្រតីក្នុងការអនុវត្តការងារ និងប្រើប្រាស់ថវិកា
- ត្រូវពិនិត្យយ៉ាងប្រុងប្រយ័ត្នអំពីនីត្យានុកូលភាពនៃការដាក់វិន័យ ឬទណ្ឌកម្មទាំងនោះ (ផ្អែកទៅលើច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ)
- ត្រូវដាក់វិន័យ ឬទណ្ឌកម្មចំពោះបុគ្គលដែលពាក់ព័ន្ធបញ្ហាមិនប្រក្រតី ដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ និងស្របតាមសមត្ថកិច្ចរបស់ខ្លួន
- ធានាឱ្យបាននូវការអនុវត្តវិធានការដាក់វិន័យ ឬទណ្ឌកម្មនានា ដែលបានកំណត់រួចហើយ
- ត្រូវដាក់ជូន ក.ត.ជ ឬ គ.ជ.វ.វ ដើម្បីពិនិត្យ និងសម្រេចចំពោះករណីទាំងឡាយណា ដែលខ្លួនមិនអាចសម្រេចបាន
- ត្រូវអនុវត្តទៅតាមអនុសាសន៍របស់ គ.ជ.វ.វ
- ត្រូវរាយការណ៍អំពីការអនុវត្តការងាររបស់ខ្លួនជូន គ.ជ.វ.វ តាមរយៈ ក.ត.ជ
- ធ្វើការកៀរគរការចូលរួមពីសង្គមស៊ីវិល ក្នុងការគាំទ្រការអនុវត្តការងាររបស់ ក.ត.ខ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និងផ្សព្វផ្សាយព័ត៌មានអំពីលទ្ធផលក្នុងការដោះស្រាយ និងឆ្លើយតបចំពោះគ្រប់បញ្ហាដែលបានប្រមូលដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយ ។

## ៣- ការបង្កើតក្រុមគាំទ្រ

ក.ត.ខ ត្រូវចេញសេចក្ដីសម្រេចដើម្បីបង្កើតក្រុមគាំទ្រដែលត្រូវជួយដល់ការអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ខ្លួន ។ តួនាទី និងភារកិច្ចរបស់ក្រុមគាំទ្រ ត្រូវកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ ក.ត.ខ ។

ក្រុមគាំទ្រនៃ គ.ត.ខ ត្រូវដឹកនាំដោយលេខាធិការរបស់ គ.ត.ខ និងមានមន្ត្រីចំនួន ០១ ដល់ ០៣ រូប បន្ថែមទៀតជាជំនួយការ ដែលត្រូវជ្រើសរើសឡើងតាមការប្រកួតប្រជែង។ ចំពោះតួនាទី និងភារកិច្ចរបស់មន្ត្រីទាំងនេះ ត្រូវកំណត់ដោយលក្ខខណ្ឌការងារដាច់ដោយឡែកដែលសម្រេចដោយ គ.ត.ខ ។

## ៤- នីតិវិធីនៃការជ្រើសរើសតំណាងឱ្យចូលជាសមាជិក គ.ត.ខ

ក្នុងការជ្រើសរើសតំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ខេត្ត ក្រុង តំណាងសង្គមស៊ីវិល និងតំណាងអ្នកទទួលការឱ្យចូលជាសមាជិកនៃ គ.ត.ខ គ.ត.ខ ត្រូវអនុវត្តតាមការណែនាំដូចមានបរិយាយក្នុងឧបសម្ព័ន្ធ ១។

## ៥- ការទទួល និងផ្សព្វផ្សាយព័ត៌មាន

គ.ត.ខ ត្រូវរៀបចំយុទ្ធសាស្ត្រក្នុងការផ្សព្វផ្សាយព័ត៌មាន ដែលពាក់ព័ន្ធនឹងដំណើរការ តួនាទី និងភារកិច្ច ព្រមទាំងសកម្មភាពរបស់ គ.ត.ខ។

គ.ត.ខ ត្រូវចែកចាយ និងផ្សព្វផ្សាយនូវសន្លឹកប័ណ្ណព័ត៌មាន ផ្ទាំងរូបភាពស្តីពីគណនេយ្យភាព ដែលនឹងត្រូវរៀបចំដោយ គ.ត.ជ និង គ.ត.ខ។

គ.ត.ខ ត្រូវរៀបចំប្រអប់សំបុត្រដោយដាក់ឈ្មោះថា "**ប្រអប់សំបុត្រគណនេយ្យភាព**"។ ប្រអប់សំបុត្រនេះត្រូវដាក់នៅទីតាំងសាធារណៈ ឬប្រជុំជនមួយចំនួននៅក្នុងឃុំ សង្កាត់ដែលធានាថា ប្រជាពលរដ្ឋមិនមានការភ័យខ្លាចនៅពេលដែលខ្លួនយកសំបុត្រអនាមិកទៅដាក់ក្នុងប្រអប់សំបុត្រគណនេយ្យភាព។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានានូវសុវត្ថិភាពប្រអប់សំបុត្រគណនេយ្យភាពដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន។ ក្រៅពីនោះ ប្រអប់សំបុត្រអាចយកទៅដាក់នៅរបងខាងមុខការិយាល័យគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ការិយាល័យគម្រោង PSDD សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីទទួលបាននូវព័ត៌មាន ឬពាក្យបណ្តឹងតវ៉ា។

គ្រប់ប្រអប់សំបុត្រគណនេយ្យភាពទាំងអស់ត្រូវតែមានសន្លឹកប័ណ្ណព័ត៌មានសម្រាប់ផ្សព្វផ្សាយ និងចែកជូនផងដែរ។

សមាជិក គ.ត.ខ ត្រូវធានាថាគ្រប់អ្នកពាក់ព័ន្ធទាំងអស់ទទួលបានសន្លឹកប័ណ្ណព័ត៌មានខាងលើ។ អ្នកពាក់ព័ន្ធទាំងអស់នោះរួមមាន ៖

- សមាជិកគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង
- មន្ត្រីរតនាគារខេត្ត ក្រុង និងមន្ត្រីសាខាធនាគារជាតិនៃកម្ពុជាខេត្ត ក្រុង
- ប្រធាន និងអនុប្រធានមន្ទីរជំនាញជុំវិញខេត្ត ក្រុង
- អ្នកសម្របសម្រួលខេត្ត ក្រុង និងស្រុក ខណ្ឌ
- មន្ត្រីគាំទ្របច្ចេកទេស
- អភិបាល និងអភិបាលរងស្រុក ខណ្ឌ
- អ្នកទទួលការ
- អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលធ្វើការងារនៅក្នុងខេត្ត ក្រុងរបស់ខ្លួន

- គ្រប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់
- សមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់
- ជនបង្គោលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ឃុំ សង្កាត់ និង
- សមាជិកគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ ។

ក.ត.ខ ត្រូវធ្វើការតាមដាន សិក្សា និងវាយតម្លៃលើយុទ្ធសាស្ត្រព័ត៌មានដែលបានអនុវត្តដើម្បីកែលម្អយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានឱ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ។

## ៦- សិទ្ធិចាត់តាំងសមាជិក និងមន្ត្រីពាក់ព័ន្ធក្នុងការបំពេញភារកិច្ច

ក្នុងករណីមានបញ្ហា ឬមានបណ្ដឹងតវ៉ាណាមួយដែលត្រូវធ្វើការស៊ើបអង្កេត ឬពិនិត្យ ប្រធាន ក.ត.ខ អាចចាត់តាំងសមាជិក ក.ត.ខ បន្ថែម ដើម្បីជួយក្រុមគាំទ្រក្នុងការទទួលខុសត្រូវលើកិច្ចការស៊ើបអង្កេតចំពោះករណីនីមួយៗនោះ ។

ក្រុមគាំទ្រនៃ ក.ត.ខ ត្រូវទទួលខុសត្រូវក្នុងការប្រមូលរបាយការណ៍ ព័ត៌មាន ឬបណ្ដឹងតវ៉ាទាំងអស់។ ផ្នែករដ្ឋបាលមូលដ្ឋានរបស់គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ត្រូវជួយក្រុមគាំទ្រក្នុងការប្រមូលរបាយការណ៍ ព័ត៌មាន ឬពាក្យបណ្ដឹងតវ៉ា ។

អ្នកប្រមូលរបាយការណ៍ ព័ត៌មាន ឬបណ្ដឹងតវ៉ាពីប្រអប់សំបុត្រ មិនអនុញ្ញាតឱ្យបើកស្រោមសំបុត្រទាំងនោះដោយមិនមានវត្តមានសមាជិក ក.ត.ខ ដែលមានសមត្ថកិច្ចនោះឡើយ ។ របាយការណ៍ ព័ត៌មាន ឬបណ្ដឹងតវ៉ាទាំងអស់ដែលប្រមូលបានត្រូវតែចុះក្នុងសៀវភៅបញ្ជីពាក្យបណ្ដឹងតវ៉ារបស់ ក.ត.ខ។ ក.ត.ខ ត្រូវពិនិត្យ និងសម្រេចជ្រើសរើសរបាយការណ៍ ព័ត៌មាន ឬបណ្ដឹងតវ៉ាណាដែលចាំបាច់ ត្រូវធ្វើការពិភាក្សា ឬស៊ើបអង្កេត ។

ក.ត.ខ អាចកំណត់នីតិវិធី និងរបៀបរបបជាក់ស្ដែងបន្ថែមទៀត ក្នុងការប្រមូលរបាយការណ៍ ព័ត៌មាន ឬពាក្យបណ្ដឹងតវ៉ា ។

## ៧- ភារកិច្ចរបស់សមាជិក ក.ត.ខ

សមាជិក ក.ត.ខ ត្រូវតែអនុវត្តតាមគោលការណ៍ដូចមានចែងក្នុងសេចក្ដីណែនាំនេះ និងសេចក្ដីសម្រេច ដែលដាក់ចេញដោយ ក.ត.ខ។ ប្រធានទីប្រឹក្សាគម្រោង PSDD ត្រូវជួយគាំទ្រ ផ្ដល់យោបល់ និងសម្របសម្រួលការងារជាប្រចាំ ដើម្បីធានាដំណើរការអនុវត្តកិច្ចការរបស់ ក.ត.ខ ប្រព្រឹត្តទៅដោយរលូន ។

សមាជិក ក.ត.ខ គ្រប់រូប ត្រូវតែចូលរួមប្រជុំឱ្យបានទៀងទាត់ ព្រមទាំងមានភារកិច្ចជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតឱ្យបានទូលំទូលាយ ។

## ៨- សិទ្ធិរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា

ប្រជាពលរដ្ឋគ្រប់រូប និងអ្នកពាក់ព័ន្ធទាំងអស់ មានសិទ្ធិរាយការណ៍ស្ដីពីបញ្ហាភាពមិនប្រក្រតីនៃការប្រើប្រាស់ថវិកាគ្រប់ប្រភេទទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតក្រោមផែនការសកម្មភាព និងថវិកាប្រចាំ

ឆ្នាំដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ និងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ តាមរយៈ "**ប្រអប់សំបុត្រគណនេយ្យភាព**" ដែលនៅជិតផ្ទះរបស់ខ្លួន។ ប្រជាពលរដ្ឋគ្រប់រូប និងអ្នកពាក់ព័ន្ធទាំងអស់អាចរាយការណ៍តាមរយៈមធ្យោបាយផ្សេងទៀត ដូចជារាយការណ៍ផ្ទាល់មាត់ រួមទាំងការរាយការណ៍តាមទូរស័ព្ទជូនទៅសមាជិក គ.គ.ខ ក៏បាន។ សមាជិក គ.គ.ខ រូបនោះត្រូវតែរៀបចំកំណត់ហេតុ ដើម្បីដាក់ជូន កិច្ចប្រជុំរបស់ គ.គ.ខ សម្រាប់ការពិភាក្សា និងសម្រេច។

## ៩- របៀបរបបប្រជុំ និងការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ គ.គ.ខ

គ.គ.ខ ត្រូវធ្វើការប្រជុំយ៉ាងតិចចំនួន ១ ដងក្នុង ១ ខែ។ កិច្ចប្រជុំរបស់ គ.គ.ខ ត្រូវតែដឹកនាំដោយប្រធាន។ ក្នុងករណីអវត្តមានរបស់ប្រធាន អនុប្រធាននឹងត្រូវដឹកនាំកិច្ចប្រជុំតាមរយៈការផ្ទេរសិទ្ធិ។

កិច្ចប្រជុំរបស់ គ.គ.ខ ត្រូវមានលិខិតអញ្ជើញដោយភ្ជាប់មកជាមួយនូវរបៀបវារៈ ហើយត្រូវចែកជូនគ្រប់សមាជិក គ.គ.ខ ឱ្យបាន ២ ថ្ងៃមុនការប្រជុំ។ ករណីចាំបាច់ជាបន្ទាន់ ការអញ្ជើញឱ្យចូលរួមប្រជុំអាចធ្វើឡើងដោយផ្ទាល់មាត់ក្នុងរយៈពេល ០៦ ម៉ោងមុនការប្រជុំ។

កិច្ចប្រជុំ គ.គ.ខ នឹងយកជាការបាន លុះត្រាតែមានវត្តមានសមាជិក គ.គ.ខ លើសពីពាក់កណ្ដាលនៃចំនួនសមាជិក គ.គ.ខ ទាំងអស់ ។

សេចក្ដីសម្រេចនៃអង្គប្រជុំរបស់ គ.គ.ខ ដែលចាត់ទុកជាបានការ លុះត្រាតែសេចក្ដីសម្រេចនោះត្រូវបានអនុម័តដោយសម្លេង ៥០ បូក ១ នៃចំនួនសមាជិក គ.គ.ខ ដែលបានចូលរួមប្រជុំ។

ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធាននៃអង្គប្រជុំមានឧត្តមានុភាព។

គ.គ.ជ និងមន្ត្រីនៃក្រុមគាំទ្រ គ.គ.ជ មានសិទ្ធិចូលរួម ដើម្បីពិនិត្យ និងសង្កេតកិច្ចប្រជុំរបស់ គ.គ.ខ ប៉ុន្តែគ្មានសិទ្ធិអនុម័តឡើយ។

គ.គ.ខ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយផ្អែកតាមគំរូបទបញ្ជាផ្ទៃក្នុង ដែលរៀបចំដោយ គ.គ.ជ ប៉ុន្តែមិនតម្រូវឱ្យយកតាមទាំងអស់នោះទេ លើកលែងតែគោលការណ៍សំខាន់ៗ។

## ១០- ដំណើរការពិនិត្យ និងដោះស្រាយពាក្យបណ្ដឹងតវ៉ា

គ.គ.ខ ត្រូវចាត់ឱ្យមានសមាជិកយ៉ាងតិច ០២ រូប ចូលរួមក្នុងការពិនិត្យមើលពាក្យបណ្ដឹងតវ៉ា ដែលក្រុមគាំទ្រប្រមូលបាន។ សមាជិកដទៃទៀតនៃ គ.គ.ខ មានសិទ្ធិចូលរួមសង្កេត និងពិនិត្យមើលដំណើរការបើកស្រោមសំបុត្រពាក្យបណ្ដឹងតវ៉ានេះ។ ក្រុមគាំទ្រត្រូវធ្វើរបាយការណ៍ពីការប្រមូល និងបើកសំបុត្រជូនអង្គប្រជុំប្រចាំខែរបស់ គ.គ.ខ ដើម្បីពិនិត្យ និងសម្រេច។

ការស៊ើបអង្កេតលើករណីណាមួយដែលសម្រេចដោយ គ.គ.ខ ត្រូវអនុវត្តតាមនីតិវិធីដែលកំណត់ដោយ គ.ជ.វ.វ។

រាល់សេចក្ដីសម្រេចក្នុងការធ្វើការស៊ើបអង្កេត និងដំណោះស្រាយចំពោះបណ្ដឹងតវ៉ាណាមួយត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ គ.គ.ខ ដោយមានសម្លេងគាំទ្រ ៥០ បូក ១ នៃសមាជិកដែលចូលរួមអង្គប្រជុំ។

ហាមដាច់ខាតចំពោះសមាជិក ក.ត.ខ ណាម្នាក់ធ្វើសេចក្ដីសម្រេចដោយពុំមានការប្រជុំ ក.ត.ខ លើដំណោះស្រាយពាក្យបណ្ដឹងតវ៉ាបានទេ។

ក្នុងករណីដែលសមាជិកណាមួយរបស់ ក.ត.ខ មានការពាក់ព័ន្ធក្នុងជម្លោះផលប្រយោជន៍នៃបណ្ដឹងតវ៉ា សមាជិក ក.ត.ខ រូបនោះមិនត្រូវអនុញ្ញាតឱ្យចូលរួមនៅក្នុងដំណើរការដោះស្រាយបណ្ដឹងតវ៉ានោះឡើយ ។

ដំណើរការ និងនីតិវិធីដោះស្រាយលើករណីបណ្ដឹងតវ៉ាណាមួយដែល ក.ត.ខ បានសម្រេចត្រូវអនុវត្តតាមនីតិវិធីដែលកំណត់ដោយ គ.ជ.វ.វ ។

ក្នុងករណីពុំទាន់មានការណែនាំថ្មីស្ដីអំពីដំណើរការពិនិត្យ និងដោះស្រាយពាក្យបណ្ដឹងតវ៉ា ក.ត.ខ ត្រូវអនុវត្តតាមនីតិវិធីដែលមានជាធរមាន ។

## ១១- វិធានការដាក់វិន័យ ឬទណ្ឌកម្ម

ក.ត.ខ ត្រូវដាក់ចេញ និងអនុវត្តនូវដាក់វិន័យ ឬទណ្ឌកម្ម។ វិធានការដាក់វិន័យ ឬទណ្ឌកម្ម ដែលមានចែងក្នុងឧបសម្ព័ន្ធ ២ គឺជាគំរូវិធានការដាក់វិន័យ ឬទណ្ឌកម្ម សម្រាប់ជាមូលដ្ឋានឱ្យ ក.ត.ខ រៀបចំវិធានការដាក់វិន័យ ឬទណ្ឌកម្មរបស់ខ្លួន។ ក្រៅពីនេះ ក.ត.ខ អាចកំណត់វិធានការដាក់វិន័យ ឬទណ្ឌកម្មផ្សេងទៀតបាន ដោយផ្អែកលើស្ថានភាពជាក់ស្ដែងរបស់ខ្លួន។

ក.ត.ខ ត្រូវពិនិត្យឡើងវិញ និងពង្រឹងលើវិធានការដាក់វិន័យ ឬទណ្ឌកម្មឱ្យតឹងរឹងបំផុតក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន ចំពោះបុគ្គលណាដែលមានការពាក់ព័ន្ធនឹងបញ្ហាភាពមិនប្រក្រតីនៃការប្រើប្រាស់ថវិកា និងការអនុវត្តការងារ ។

ក.ត.ខ ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះការដាក់វិន័យ ឬទណ្ឌកម្មលើគ្រប់ករណីទាំងអស់ ដែលក្រសួង ស្ថាប័ន ឬអង្គភាពបានអនុវត្ត ។

## ១២- ការអនុវត្តសេចក្ដីសម្រេចរបស់ ក.ត.ខ

ក.ត.ខ ត្រូវផ្ញើសេចក្ដីសម្រេចរបស់ខ្លួនទៅផ្នែក និងអង្គភាពនៃគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង មន្ទីរជំនាញជុំវិញខេត្ត ក្រុង និងស្ថាប័នពាក់ព័ន្ធនានា យ៉ាងយូរក្នុងរយៈពេល ៥ ថ្ងៃធ្វើការងារ បន្ទាប់ពីដាក់ចេញសេចក្ដីសម្រេចនោះ ព្រមទាំងចម្លង ០១ ច្បាប់ជូន ក.ត.ជ ។

ផ្នែកនៃគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង មន្ទីរជំនាញជុំវិញខេត្ត ក្រុង និងស្ថាប័នពាក់ព័ន្ធនានា ត្រូវតែអនុវត្តតាមឱ្យបានម៉ឺងម៉ាត់នូវសេចក្ដីសម្រេចនៃអង្គប្រជុំរបស់ ក.ត.ខ យ៉ាងយូរក្នុងរយៈពេល ១៥ ថ្ងៃធ្វើការងារ បន្ទាប់ពីបានទទួលសេចក្ដីសម្រេចនេះ ។

ក.ត.ខ ត្រូវផ្ញើជូន ក.ត.ជ នូវផែនការសកម្មភាព និងរបាយការណ៍រីកចម្រើន ដោយឆ្លុះបញ្ចាំងនូវដំណើរការអនុវត្ត និងលទ្ធផលដែល ក.ត.ខ សម្រេចបាន។

## ១៣- ការជួលទីប្រឹក្សាច្បាប់

គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុងត្រូវគ្រោងថវិកាមួយចំនួនសម្រាប់ជួលទីប្រឹក្សាច្បាប់ ឬមេធាវី ដើម្បីផ្តល់យោបល់អំពីទិដ្ឋភាពច្បាប់ និងការពារសេចក្តីសម្រេចរបស់ ក.ត.ខ ក្នុងករណីដែលសេចក្តីសម្រេចនោះ ត្រូវបានបញ្ជូនទៅតុលាការ ។ ការជួលនេះ អាចធ្វើឡើងផ្អែកតាមករណីចាំបាច់ ដោយមានលក្ខខណ្ឌការងារច្បាស់លាស់ ។

## ១៤- ការិយាល័យរបស់ ក.ត.ខ

ការិយាល័យ ក.ត.ខ មានទីតាំងនៅក្នុងការិយាល័យគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ។ ចំណាយសម្រាប់ប្រតិបត្តិការរបស់ ក.ត.ខ ត្រូវប្រើប្រាស់តាមរយៈថវិការបស់គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ក្នុងខ្ទង់ថវិកាមួយជាក់លាក់ ។

អភិបាលខេត្ត ក្រុង មន្ទីរជំនាញជុំវិញខេត្ត ក្រុង និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ប្រធាន

ស ខេង

**ចម្លងជូន**
- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.វ.វ
- ធនាគារជាតិនៃកម្ពុជា
- ក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ
- សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់
  (ដើម្បីជូនជ្រាប)
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ ១

# នីតិវិធីនៃការជ្រើសរើសតំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងសង្គមស៊ីវិល និងតំណាងអ្នកទទួលការឱ្យចូលជាសមាជិក គ.គ.ខ

## ១-ការជ្រើសរើសតំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ ឬតំណាងក្រុមប្រឹក្សាឃុំ សង្កាត់

គ.គ.ខ ត្រូវជូនដំណឹងដល់សមាគមក្រុមប្រឹក្សាឃុំ សង្កាត់ខេត្ត ក្រុងឱ្យធ្វើការជ្រើសរើសតំណាងរបស់ខ្លួនចំនួន ០៣ រូប ដែលមានសមាសភាពមកពីគណៈបក្សនយោបាយផ្សេងៗគ្នា ដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សា។

ក្នុងករណីខេត្ត ក្រុងណាមួយគ្មានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ខេត្ត ក្រុង សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ចែងរៀបចំធ្វើការជ្រើសរើសតំណាងក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ០៣ រូប ដែលមកពីគណបក្សនយោបាយផ្សេងៗគ្នា ដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យចូលជាសមាជិកភាព គ.គ.ខ។

ការជ្រើសរើសតំណាងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទាំង ០៣ រូប ត្រូវយកចិត្តទុកដាក់លើ ៖

- សមត្ថភាព
- ការទទួលខុសត្រូវខ្ពស់
- មកពីតំបន់ផ្សេងគ្នា និង
- មានឆន្ទៈបំរើការងារជាសមាជិក គ.គ.ខ។

## ២-ការជ្រើសរើសតំណាងសង្គមស៊ីវិល និងតំណាងអ្នកទទួលការ

ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ដោយមានជំនួយពីប្រធានទីប្រឹក្សាគម្រោង PSDD ប្រចាំខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំ ២ ដាច់ដោយឡែកពីគ្នា ៖

- កិច្ចប្រជុំជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការងារនៅក្នុងខេត្ត ក្រុងរបស់ខ្លួន
- កិច្ចប្រជុំជាមួយអ្នកទទួលការដែលអាជីវកម្មរបស់ពួកគេស្ថិតនៅក្នុងខេត្ត ក្រុងសាមី។

នៅក្នុងកិច្ចប្រជុំនីមួយៗ ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ត្រូវជម្រាបអំពីគោលបំណងនៃការប្រជុំដើម្បីជ្រើសរើសតំណាងចំនួន ០២ រូប សម្រាប់ធ្វើជាសមាជិក គ.គ.ខ។ ក្នុងកិច្ចប្រជុំនេះត្រូវផ្សព្វផ្សាយអំពី ៖

- គោលបំណងនៃការបង្កើត គ.គ.ខ
- សមាជិកភាពនៃ គ.គ.ខ
- តួនាទី មុខងារ និងភារកិច្ចរបស់ គ.គ.ខ
- នីតិវិធីធ្វើការងាររបស់ គ.គ.ខ។

ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងក៏ត្រូវរំលឹកផងដែរដល់អ្នកចូលរួមដែលជាអ្នកទទួលការទាំងអស់ថា ដើម្បីឱ្យដំណើរការមានប្រសិទ្ធភាព តំណាងអ្នកទទួលការគួរតែមានលក្ខណៈសម្បត្តិសមស្រប និងមិនធ្លាប់មានក្នុងបញ្ជីឈ្មោះអ្នកទទួលការដែលត្រូវបានដកសិទ្ធិក្នុងការដាក់សំណើដេញថ្លៃ ។

បន្ទាប់មកប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងត្រូវទុកពេលវេលាឱ្យបានគ្រប់គ្រាន់ ដើម្បីផ្តល់ឱកាសដល់សមាជិកអង្គប្រជុំសួរជាសំណួរផ្សេងៗ ។ ជាបន្តទៀត ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានត្រូវអនុញ្ញាតឱ្យអ្នកចូលរួមអង្គប្រជុំពិភាក្សាគ្នា ដើម្បីជ្រើសរើសតំណាងរបស់ខ្លួនចំនួន ០២ រូប ។ ការជ្រើសរើសតំណាងនីមួយៗនេះ អាចធ្វើឡើងតាមនីតិវិធីសមស្របណាមួយដែលមានលក្ខណៈជាក់ស្តែង និងសាមញ្ញ ។

បន្ទាប់ពីការជ្រើសរើសតំណាងបានហើយ ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានត្រូវប្រកាសជាផ្លូវការនូវឈ្មោះអ្នកតំណាងដែលបានជ្រើសរើសសម្រាប់ធ្វើជាសមាជិកក្រុមការងារគណនេយ្យភាពខេត្ត ក្រុង ។

អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងត្រូវធ្វើកំណត់ហេតុស្តីពីកិច្ចប្រជុំជ្រើសរើសតំណាងទាំងនេះ ។

ឧបសម្ព័ន្ធ ២

# គំរូលិខិតរដ្ឋបាលការដាក់វិន័យ ឬទណ្ឌកម្ម

ថ្ងៃទី.......ខែ..........ឆ្នាំ២០០... គ.គ.ខ............. បានអនុម័តនូវវិធានការដាក់វិន័យ ឬទណ្ឌកម្មចំពោះបុគ្គល ដែលពាក់ព័ន្ធនឹងបញ្ហាភាពមិនប្រក្រតីនៃការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការសកម្មភាព និងថវិកាដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ និងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ជុំវិញការអនុវត្តផែនការសកម្មភាព និងថវិកាដែលបានមកពីប្រភពគាំទ្ររបស់ គ.ជ.វ.វ ដូចខាងក្រោម ÷

១- មន្ត្រីនៃផ្នែកណាមួយរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ដែលពាក់ព័ន្ធនៅក្នុងបញ្ហា**ភាពមិនប្រក្រតី** (១) ឬមិនបានរាយការណ៍អំពីភាពមិនប្រក្រតីនេះទៅ គ.គ.ខ កិច្ចសន្យាបំរើការងាររបស់មន្ត្រីគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុងនោះនឹងត្រូវបានបញ្ចប់ភ្លាម ។ លើសពីនេះ មន្ត្រីទាំងនេះអាចទទួលនូវការពិន័យជាប្រាក់ថែមទៀតផង ។ អភិបាលខេត្ត ក្រុងត្រូវធ្វើរបាយការណ៍ផ្ញើជូនក្រសួង ស្ថាប័នសាមីដើម្បីស្នើសុំដាក់វិន័យ ឬទណ្ឌកម្មដោយយោងតាមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

២- បុគ្គលិកគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ដែលពាក់ព័ន្ធនៅក្នុងបញ្ហាភាពមិនប្រក្រតី ឬមិនបានរាយការណ៍អំពីភាពមិនប្រក្រតីនេះទៅ គ.គ.ខ កិច្ចសន្យាបំរើការងាររបស់បុគ្គលិកនោះនឹងត្រូវបានបញ្ចប់ភ្លាម ។ លើសពីនេះ បុគ្គលិកទាំងនេះអាចទទួលនូវការពិន័យជាប្រាក់ថែមទៀតផង ។

៣- មន្ត្រីធនាគារដែលប្រព្រឹត្តមិនត្រឹមត្រូវ ឧទាហរណ៍ដូចជាការទាមទារកំរៃក្រៅផ្លូវការពីអ្នកទទួលការ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬស្មៀនឃុំ សង្កាត់ កិច្ចសន្យាបំរើការងាររបស់មន្ត្រីរូបនោះនឹងត្រូវបញ្ចប់ភ្លាម ។ ទន្ទឹមនេះ អភិបាលខេត្ត ក្រុង ត្រូវរៀបចំរបាយការណ៍ស្តីពីការបំពេញការងារជាមួយគណៈកម្មាធិការប្រតិបត្តិរបស់មន្ត្រីធនាគាររូបនោះ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំដាក់វិន័យ ឬទណ្ឌកម្ម ដោយយោងតាមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងចម្លងជូនធនាគារជាតិមួយច្បាប់ ។

៤- បុគ្គលិកសាខាធនាគារជាតិនៃកម្ពុជាតាមបណ្តាខេត្ត ក្រុងដែលបានប្រព្រឹត្តមិនត្រឹមត្រូវ ឧទាហរណ៍ដូចជាការទាមទារកំរៃក្រៅផ្លូវការ ឬការកាត់ប្រាក់ដោយមិនស្របច្បាប់ពីអ្នកទទួលការ ក្រុមប្រឹក្សាឃុំ សង្កាត់ ឬស្មៀនឃុំ សង្កាត់ បុគ្គលិករូបនោះនឹងត្រូវទទួលការព្រមាន និងទណ្ឌកម្មស្របតាមបទប្បញ្ញត្តិដែលបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ។ អភិបាលខេត្ត ក្រុងត្រូវរាយការណ៍អំពីការដាក់ទណ្ឌកម្មដល់បុគ្គលិករូបនោះមក គ.ត.ជ ។ ក្នុងករណីនេះ ប្រសិនបើធនាគារជាតិនៃកម្ពុជា មិនបានអនុវត្តវិធានការត្រឹមត្រូវ និងទាន់ពេលវេលាទៅលើបុគ្គលដែលពាក់ព័ន្ធនោះទេ គ.ជ.វ.វ ត្រូវពិចារណាពិនិត្យនូវជម្រើសផ្សេងទៀតសម្រាប់ប្រតិបត្តិការលំហូមូលនិធិ ទៅថ្នាក់ក្រោមជាតិក្រៅពីប្រព័ន្ធធនាគារជាតិនៃកម្ពុជា ។

៥- អ្នកសម្របសម្រួលខេត្ត ក្រុង និងស្រុក ខណ្ឌ ដែលពាក់ព័ន្ធនៅក្នុងភាពមិនប្រក្រតីណាមួយ ដូចជាការគិតថ្លៃឈ្នួលពីឃុំ សង្កាត់បន្ថែមចំពោះការគាំទ្ររបស់ខ្លួន កិច្ចសន្យាបំរើការងារជាមួយគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង របស់អ្នកសម្របសម្រួលខេត្ត ក្រុង និងស្រុក ខណ្ឌនោះនឹងត្រូវបានបញ្ចប់ភ្លាម ។

៦- មន្ត្រីគាំទ្របច្ចេកទេស អ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកផ្តល់សេវាផ្ទាល់ដទៃទៀតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានចុះកិច្ចសន្យាជាមួយគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង បានបន្លំចុះឈ្មោះរបស់ខ្លួនក្នុងបញ្ជីជាអ្នកទទួលការនៃគម្រោងមូលនិធិឃុំ សង្កាត់ ឬបានចុះឈ្មោះក្នុងបញ្ជីជាអ្នកទទួលការ កិច្ចសន្យាបំរើការងាររបស់មន្ត្រីនៃគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុងនោះនឹងត្រូវបានបញ្ចប់ភ្លាម ។

៧- ករណីមន្ត្រីគាំទ្របច្ចេកទេសនៃគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ចុះហត្ថលេខាលើរបាយការណ៍រីកចម្រើន ឬរបាយការណ៍បញ្ចប់គម្រោងដោយមិនបានចុះពិនិត្យជាក់ស្តែងដោយផ្ទាល់នៅទីតាំងគម្រោង ឬបានចុះត្រួតពិនិត្យដោយមានការបន្លែបន្លំ ឬឃុបឃិតគ្នា កិច្ចសន្យាបំរើការងារជាមួយគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុងរបស់មន្ត្រីគាំទ្របច្ចេកទេសរូបនោះនឹងត្រូវបានបញ្ចប់ភ្លាម ។

៨- ករណីមានភស្តុតាងនៃការស៊ីមគ្រលុំណាមួយជាមួយអ្នកទទួលការ កិច្ចសន្យាបំរើការងាររបស់មន្ត្រីគាំទ្របច្ចេកទេស និងអ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌជាមួយគណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង នឹងត្រូវបញ្ចប់ភ្លាម ។ គ.ត.ខ ត្រូវរៀបចំរបាយការណ៍ជាផ្លូវការមួយផ្ញើជូនក្រសួង ស្ថាប័ន និងមន្ទីរសាមីពាក់ព័ន្ធដើម្បីស្នើសុំដាក់វិន័យ ឬទណ្ឌកម្ម ដោយយោងទៅតាមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។ ទន្ទឹមនេះ អ្នកទទួលការពាក់ព័ន្ធត្រូវលុបឈ្មោះចេញពីបញ្ជីអ្នកទទួលការ ។

៩- អ្នកទទួលការដែលមិនបានរាយការណ៍អំពីការស្នើសុំ ឬការកាត់ប្រាក់មិនស្របច្បាប់ ដោយបុគ្គលិករតនាគារ ឬបុគ្គលិកសាខាធនាគារជាតិនៃកម្ពុជា មន្ត្រីគាំទ្របច្ចេកទេស អ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធដទៃទៀត អ្នកទទួលការនោះត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការ និងមិនអនុញ្ញាតឱ្យចូលរួមដេញថ្លៃគម្រោងដែលស្ថិតនៅក្នុងផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ ។

១០- អ្នកទទួលការដែលយល់ព្រមឱ្យលុយកាក់មិនស្របច្បាប់ ( ជាសំណូកសូកប៉ាន់ ) ដល់បុគ្គលិករតនាគារ ឬបុគ្គលិកសាខាធគារជាតិនៃកម្ពុជា ឬអ្នកពាក់ព័ន្ធដទៃទៀត អ្នកទទួលការរូបនោះនឹងត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការភ្លាម និងមិនអនុញ្ញាតឱ្យចូលរួមដេញថ្លៃគម្រោង ដែលស្ថិតនៅក្នុងផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ ។

១១- អ្នកទទួលការមិនត្រូវចំណាយថវិកាសម្រាប់ពិធីជប់លៀងបើក និងបិទការដ្ឋានឡើយ ។ គ.ត.ខ ត្រូវតែធ្វើការព្រមានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬភាគីណាមួយដែលនៅតែទាមទារឱ្យអ្នកទទួលការចំណាយ ដើម្បីរៀបចំពិធីជប់លៀងទាំងនេះ ។ ប្រសិនបើមិនរាងចាល គ.ត.ខ ត្រូវពិចារណាដាក់វិន័យ ឬទណ្ឌកម្មលើបុគ្គលនោះ ដោយផ្អែកលើបទប្បញ្ញត្តិដែលពាក់ព័ន្ធ និងថ្លឹងថ្លែងទៅតាមទំហំនៃកំហុសឆ្គងដែលបានប្រព្រឹត្ត ។

១២- ស្មៀនឃុំ សង្កាត់ដែលយល់ព្រមចុះហត្ថលេខាទទួលយកប្រាក់មិនគ្រប់ចំនួនពីមន្ត្រីសាខាធនាគារជាតិនៃកម្ពុជា ស្មៀនឃុំ សង្កាត់រូបនោះ នឹងត្រូវធ្វើការព្រមានជាលាយលក្ខណ៍អក្សរដោយអភិបាលខេត្ត ក្រុងជាលើកទី១ ។

ករណីមិនរាងចាល អភិបាលខេត្ត ក្រុង ដោយមានប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានជាជំនួយការ ត្រូវរៀបចំឯកសារផ្ទេរការផ្ញើជូនក្រសួងមហាផ្ទៃ ដើម្បីស្នើសុំដាក់វិន័យ ឬទណ្ឌកម្មដោយយោងតាមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

១៣- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយ ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងបញ្ហាភាពមិនប្រក្រតីជាលើកទី១ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់រូបនោះត្រូវបានទទួលការព្រមានជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាឃុំ សង្កាត់សាមី ។ ករណីមិនរាងចាល គ.ត.ខ ត្រូវពិចារណាសម្រេចដាក់វិន័យ ឬទណ្ឌកម្មស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

១៤- ស្មៀនឃុំ សង្កាត់ណាមួយដែលភូតកុហកក្រុមប្រឹក្សាឃុំ សង្កាត់ថាមន្ត្រីរតនាគារ ឬមន្ត្រីសាខាធនាគារជាតិនៃកម្ពុជាខេត្ត ក្រុង បានយកលុយជាសាគុនចំនួនច្រើនលើសលុបពីការពិត ស្មៀនឃុំ សង្កាត់រូបនោះត្រូវបានទទួលការព្រមានជាលាយលក្ខណ៍អក្សរពីក្រុមប្រឹក្សាឃុំ សង្កាត់សាមី ។ ករណីមិនរាងចាល គ.ត.ខ ត្រូវពិចារណាសម្រេចដាក់វិន័យ ឬទណ្ឌកម្មស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ។

១៥- មន្ត្រីនៃមន្ទីរវិស័យ ដែលពាក់ព័ន្ធនៅក្នុងបញ្ហាភាពមិនប្រក្រតី ឬមិនបានរាយការណ៍អំពីភាពមិនប្រក្រតីនេះ ទៅ គ.ត.ខ កិច្ចសន្យាបំរើការងាររបស់មន្ត្រីនៃមន្ទីរវិស័យនោះនឹងត្រូវបានបញ្ចប់ភ្លាម ។ លើសពីនេះ អភិបាលខេត្ត ក្រុងត្រូវស្នើជាលាយលក្ខណ៍អក្សរទៅក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធដើម្បីចាត់វិធានការតាមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

១៦- មន្ត្រីទាំងឡាយដែលពាក់ព័ន្ធទៅនឹងភាពមិនប្រក្រតីនៃការប្រើប្រាស់ថវិកានៅថ្នាក់ស្រុក ខណ្ឌ ឬមិនបានរាយការណ៍អំពីភាពមិនប្រក្រតីនេះទៅ គ.ត.ខ កិច្ចសន្យាបំរើការងាររបស់មន្ត្រី ដែលពាក់ព័ន្ធនៅថ្នាក់ស្រុក ខណ្ឌនោះនឹងត្រូវបានបញ្ចប់ភ្លាម ។ លើសពីនេះ អភិបាលខេត្ត ក្រុង ត្រូវស្នើទៅក្រសួង ស្ថាប័នសាមី ដើម្បីចាត់វិធានការតាមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

១៧- មន្ត្រី និងអាជ្ញាធរមានសមត្ថកិច្ចក្នុងខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលត្រូវអនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងរដ្ឋបាលដែនដីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានការពាក់ព័ន្ធទៅនឹងភាពមិនប្រក្រតីនៃការអនុវត្តការងាររបស់ខ្លួន មន្ត្រី និងអាជ្ញាធរនោះនឹងត្រូវទទួលនូវការដាក់វិន័យ ឬទណ្ឌកម្មស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ ។

១៨- បុគ្គលិកគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលគាំទ្រដល់ការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ ត.ជ.វ.វ ដែលមានការពាក់ព័ន្ធនឹងភាពមិនប្រក្រតី ឬមិនបានរាយការណ៍អំពីភាពមិនប្រក្រតីនេះទៅ គ.ត.ខ បុគ្គលិករូបនោះនឹងត្រូវទទួលការដាក់វិន័យ ឬទណ្ឌកម្មដោយផ្អែកតាមគោលការណ៍របស់ដៃគូអភិវឌ្ឍន៍ ឬអង្គការនោះ ។

**សំគាល់:** “ **១** ” **ភាពមិនប្រក្រតី** សំដៅលើការអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍ណែនាំ ឬនីតិវិធីក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភេទទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ ត.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ និងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។